**ការវិភាគករណី សាយរីន**

បណ្តាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ (សាយរីន=SIREN)

**គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិប្រឆាំងនឹងការជួញដូរមនុស្ស (UNIAP): ជំហានទី ៣**

**ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ CB-03

# ការកេងប្រវ័ញ្ចលើបុរសកម្ពុជា នៅលើផ្ទៃសមុទ្រ

## រឿងពិតអំពីការជួញដូរបុរសកម្ពុជាទៅធ្វើការលើទូកនេសាទថៃ

| | |
|---|---|
| **ពាក្យគន្លឹះ** | ▪ **ទីតាំង :** កម្ពុជា ថៃ ម៉ាឡេស៊ី<br>▪ **ប្រធានបទ :** ការជ្រើសរើស ការកេងប្រវ័ញ្ចលើពលកម្ម ឧស្សាហកម្មនេសាទ<br>▪ **ប្រភេទព័ត៌មាន :** ការវិភាគករណីនៃបេសកកម្មរយៈពេល ១៨ ខែ n=៤៩ |
| **សេចក្តីសង្ខេប** | *សន្លឹកព័ត៌មានស្តីពីការជ្រើសរើស ការជួញដូរ និងការកេងប្រវ័ញ្ចលើបុរសកម្ពុជា ឱ្យទៅធ្វើការលើទូកនេសាទថៃ ដោយផ្អែកលើករណីជនរងគ្រោះចំនួន ៤៩ នាក់ ដែលបានគេចខ្លួននៅក្នុងប្រទេសថៃ ឬ ម៉ាឡេស៊ី និងដែលបានទទួលការជួយសង្គ្រោះឱ្យវិលត្រឡប់មកផ្ទះវិញ ។* |
| **អ្នកនិពន្ធ** | UNIAP UNITED NATIONS INTER-AGENCY PROJECT ON HUMAN TRAFFICKING [១] |

*បុរស ស្ត្រី និងកុមារកម្ពុជា ដែលបាន ប៉ាន់ប្រមាណថាមានចំនួនច្រើនពាន់នាក់ត្រូវបានជួញដូរទៅប្រទេសថៃជារៀងរាល់ឆ្នាំ ក្នុងបំណងនៃការកេង ប្រវ័ញ្ចលើកម្លាំងពលកម្ម ។ ករណីអាក្រក់បំផុតខ្លះៗនៃការកេង-ប្រវ័ញ្ច គឺ បុរស និងកុមារ ដែលត្រូវគេបោកបញ្ឆោតឱ្យទៅ ធ្វើការលើទូកនេសាទរយៈពេលយូរ ដែលជាទូកនេសាទនៅក្នុងដែន ទឹកនៃសមុទ្រចិនខាងត្បូង ដែលរួមទាំងនៅក្នុងដែនទឹកនៃប្រទេសម៉ាឡេស៊ីផងដែរ [២] ។ ទូកទាំងនេះ ដែលចេញទៅនេសាទនៅសមុទ្ររហូត*

*ដល់រយៈពេល២ឆ្នាំ ឬលើសពីនេះ បានក្លាយជាពន្ធនាគារជាក់ ស្តែងដែលនៅលើទូកទាំងនោះជន រង-គ្រោះពីការជួញដូរ ត្រូវទ្រាំទ្រក្នុងលក្ខខណ្ឌការងារប្រកប ដោយអមនុស្សធម៌ និងការបំពារបំពានលើរូបកាយ ។ ការសម្លាប់ជីវិតមនុស្សទម្លាក់ចូលទៅក្នុងទឹកសមុទ្រកើតមានជាញឹកញាប់ ដែលជួនកាល ដោយ*

---

[១] របាយការណ៍នេះ ឆ្លុះបញ្ចាំងពីកិច្ចសហការ និងការស្វែងយល់ដោយទីភ្នាក់ងារជាច្រើន ដែលពាក់ព័ន្ធនៅក្នុងករណីទាំងនេះ ដោយរួមទាំងដៃគូមិនមែនរដ្ឋាភិបាល ដូចជា IOM, LICADHO និង LSCW នៅកម្ពុជា និង Tenaganita នៅម៉ាឡេស៊ី និងដៃគូមកពីរដ្ឋាភិបាល ដូចជា MoFA, MoSAVY និង MoWA នៅកម្ពុជា អាជ្ញាធរអន្តោប្រវេសន៍នៅម៉ាឡេស៊ី និង MOJ's DSI នៅប្រទេសថៃឡង់ដ៏ ។

[២] Olivie, Andre (២០០៨) ការកំណត់អត្តសញ្ញាណជនកម្ពុជារងគ្រោះដោយការ ជួញដូរក្នុងចំណោមជនដែលត្រូវបានគេនិរទេសពីប្រទេសថៃ UNIAP.

*សារមេការនាវិក ។ វិធីតែមួយគត់គឺ លួចរត់គេចដោយលោតចេញ នៅពេលទូកចូលចតដើម្បី ចុះបញ្ជីការ/បំពេញសំណុំឯកសារនៅកន្លែងនានា ដូចជា សារ៉ាវ៉ាក់ ប្រទេសម៉ាឡេស៊ី ។*

*របាយការណ៍* ***សាយរីន*** *សង្ខេបនូវព័ត៌មានពិតអំពីការជួញដូរ បុរស និងកុមារកម្ពុជា ចំនួន ៤៩ នាក់ ឱ្យទៅធ្វើការនៅលើទូក នេសាទថៃសម្រាប់ រយៈពេលវែង និងដែលត្រូវបានសង្គ្រោះនៅក្នុង រយៈពេល ១៨ ខែកន្លងមកនេះ ដោយបណ្ដាញអ្នកឆ្លើយតប ដែលមាននៅក្នុងប្រទេសកម្ពុជា ថៃ និងម៉ាឡេស៊ី ។ ករណីដែល បុរស និងកុមារទាំងនេះបានប្រឈមមានភាពខុសគ្នាខ្លះៗប៉ុន្តែប្រធានបទទូទៅគឺ ការបោក-ប្រាស់ និងបន្ទុកនៃបំណុលដែលបង្ក ដោយ មេខ្យល់មួយ ឬច្រើន ដែលជាជនជាតិខ្មែរ និងថៃ ការលក់អ្នកទាំងនោះទៅឱ្យថៅកែទូកនេសាទថៃ ក្នុងតម្លៃ ១០០០០-១៥០០០បាត[៣] ដើម្បីធ្វើការលើ ទូកនេសាទក្នុងដែនសមុទ្រ ដូចជាទាសករ មានទាំងការវាយដំ ការបង្អត់អាហារ ការបង្ខំ ឱ្យធ្វើការជាច្រើនម៉ោងដូចសត្វធាតុ (ឧទាហរណ៍ ធ្វើការរយៈពេល ៣ថ្ងៃ ៣យប់ បន្តជាប់រហូត នៅពេលត្រូវជួសអួន) កង្វះការ ព្យាបាលជម្ងឺ ឬ របួស និងការគម្រាមសម្លាប់ចោល និងជួនកាលត្រូវបាន គេ រាយការណ៍ថាមានការធ្វើឃាដផងដែរ ។*

*ជនរងគ្រោះមួយចំនួនបានគេចចេញពីទាសភាពនេះ ដោយ រត់គេចខ្លួន ប៉ុន្តែជាញឹកញាប់ ការឈឺចាប់របស់ពួកគេ មិនបញ្ចប់ ត្រឹមនេះទេ ។*

*នៅសារ៉ាវ៉ាក់ នៃប្រទេស ម៉ាឡេស៊ី មេខ្យល់បង្ខំបុរស*

*និងកុមារទាំងនេះឱ្យធ្វើ ពលកម្មនៅក្នុងចំការដូងប្រេង និងចំការកៅស៊ូ ដោយសារភាពងាយស្រួលក្នុងការជួលអ្នកទាំងនេះ ព្រោះថាអ្នក ទាំងនេះគេចចេញពីទូកនេសាទថៃ និង ដោយសារភ្នាក់ងាររបស់ពួក មេខ្យល់ទាំងនោះ ដែល ប្រតិបត្តិការនៅក្បែរកំពង់ផែនោះ ។*

*ជនរង គ្រោះខ្លះត្រូវបានមន្ត្រីនគរបាល ឬមន្ត្រីអន្តោ - ប្រវេសន៏កត់សំគាល់ក្រៅពីមេខ្យល់(ដែលជួនកាលនាំទៅរកការចាប់ខ្លួន ការផាកពិន័យ វាយនឹងដំបង និងការនិរទេស ជួនកាលឈានឱ្យទៅធ្វើការងារនៅក្នុងចំការធំៗ) ។*

*ជនរងគ្រោះខ្លះប្រគល់ខ្លួនទៅអាជ្ញាធរភ្លាមៗដោយសង្ឃឹមថានឹងត្រូវបញ្ជូនត្រឡប់មកប្រទេសកំណើតវិញ ។ ប៉ុន្តែគ្មាននរណាម្នាក់ត្រូវបានគេចាត់ទុកថា ជាជនរងគ្រោះដោយ សារការជួញដូរឡើយ ។*

[៣] ប្រមាណ ២៨៧-៤៣០ ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់សព្វថ្ងៃនេះ ពោលគឺ ៣៤,៨ បាត = ១ ដុល្លា ។

## សេចក្តីសង្ខេបអំពីករណី

**បុរស និងកុមារកម្ពុជាចំនួន ៤៩ នាក់ត្រូវបានជួញដូរឱ្យទៅធ្វើការនៅលើទូកនេសាទថៃ រយៈពេលវែង និងត្រូវបាន សង្គ្រោះនៅក្នុងប្រទេសថៃ ឬ ម៉ាឡេស៊ី ក្នុងរវាងខែ មិថុនា ឆ្នាំ ២០០៧-ខែ ធ្នូ ឆ្នាំ ២០០៨ (រយៈពេល ១៨ខែ)**

ករណីនានាដែលត្រូវបានរាប់បញ្ចូលនៅក្នុងការវិភាគនេះគឺ បុរស និងកុមារកម្ពុជា ដែលត្រូវគ្នានឹងលក្ខណៈវិនិច្ឆ័យចំនួនបួន : (១) អ្នក ទាំងនោះរងការជួញដូរឱ្យទៅធ្វើការនៅលើទូកនេសាទថៃ (២)អ្នកទាំងនោះបានគេចខ្លួនពីទូកនេសាទ (៣) អ្នកទាំងនោះត្រូវបានរកឃើញ និងជួយសង្គ្រោះនៅក្នុងរយៈពេល ១៨ ខែចុងក្រោយនេះ ដោយបណ្តាញអ្នកឆ្លើយតបនៅកម្ពុជា ថៃ និងម៉ាឡេស៊ី និង (៤) អ្នកទាំងនោះ បានវិលត្រលប់មកកម្ពុជាវិញដោយសុវត្ថិភាព។ បុរស និងកុមារទាំងនោះ ត្រូវបានធ្វើសម្ភាសជាភាសាខ្មែរ ដោយបុគ្គលិកគម្រោង UNIAP នៅក្នុង ឬនៅជិតភូមិកំណើតរបស់ពួកគេ។

មានករណីជាច្រើនស្រដៀងគ្នានេះ ដែលរដ្ឋាភិបាល និងអ្នកឆ្លើយតបពីអង្គការ មិនមែនរដ្ឋាភិបាល បានជួយសង្គ្រោះ មុនរយៈពេល រាយការណ៍នេះ ហើយក៏មានករណីជាច្រើនទៀតផងដែរដែល "កំពុងអនុវត្ត" ដោយជនរងគ្រោះត្រូវបានតាមរក និងបានរកឃើញ ប៉ុន្តែនៅពុំទាន់បានវិល ត្រឡប់មកផ្ទះវិញដោយសុវត្ថិភាព នៅឡើយទេ។ យើងពុំបានរាប់បញ្ចូលករណីទាំងនេះឡើយពីព្រោះពុំទាន់មានព័ត៌មានច្បាស់លាស់នៅឡើយ។

## *ខេត្តជាប្រភពដើមរបស់ជនរងគ្រោះទាំង ៤៩ នាក់ នៅក្នុងប្រទេសកម្ពុជា និងគោលដៅ នៅក្នុងប្រទេសថៃ*

១០ នាក់ ក្នុងចំណោមអ្នករងគ្រោះជាបុរស និងកុមារចំនួន ៤៩ នាក់ មកពីខេត្តបន្ទាយមានជ័យ និង ១១ នាក់មកពីខេត្តកណ្តាល។ តួលេខខ្ពស់មកពីខេត្តទាំងពីរនេះ គឺដោយសារករណីពីរ ក្នុងចំណោមករណីចម្បងនានា នៅក្នុងរយៈពេល ១៨ ខែ ចុង ក្រោយនេះ ត្រូវបានរាយការណ៍ដោយសមាជិកគ្រួសារនៅក្នុងខេត្តទាំងពីរនេះ ដែលបុរសជាចំនួនច្រើនត្រូវបានជួញដូរ*ជាក្រុម* ឱ្យទៅធ្វើការនៅលើទូកតែមួយ។ ជាសរុបបុរសចំនួន ៤៩នាក់មានប្រភពចេញពីខេត្តចំនួន ១៣ដែលជារបាយយ៉ាងទូលំទូលាយ នៅក្នុងប្រទេសកម្ពុជា។ នៅប្រទេសថៃ ជនរងគ្រោះ ៥៧% ត្រូវបានជួញដូរឱ្យទៅធ្វើការលើ ទូកនេសាទនៅ ប៉ាក់ណាម ខេត្តសាមុតប្រាកាន និង ៣១% ត្រូវបានជួញដូរ ឱ្យទៅធ្វើការ លើទូកនៅក្នុង ខេត្តសុងក្លា។

បើគិតពីអាយុ ១៨%នៃជនរងគ្រោះចំនួន ៤៩ នាក់ គឺជាកុមារ នៅក្នុងពេលដែលពួកគេត្រូវបានជ្រើសរើស និងបង្ខំឱ្យទៅធ្វើការនៅលើ ទូកនេសាទ អ្នកដទៃទៀតជាមនុស្សពេញវ័យ។




ផែនទីប្រទេសកម្ពុជា (ខាងឆ្វេង) : ខេត្តជាប្រភពដើមនៃជនរងគ្រោះ (រាប់តាមលំដាប់ពីច្រើនទៅតិច): កណ្តាល (១១នាក់) បន្ទាយមានជ័យ (១០នាក់) សៀមរាប (៥ នាក់) តាកែវ (៥នាក់) បាត់ដំបង និងកំពង់ធំ (មួយខេត្ត ៤នាក់) ឧត្តរមានជ័យ កំពង់ចាម និងព្រៃវែង (មួយខេត្ត ២នាក់) ស្ទឹងត្រែង កំពង់ស្ពឺ កំពត និង ភ្នំពេញ (មួយខេត្ត-ក្រុង ១នាក់) ។




ផែនទីប្រទេសថៃ (ខាងស្តាំ) : ខេត្តជាទីដៅ ដែលជនរងគ្រោះកម្ពុជាត្រូវបានបង្ខំឱ្យធ្វើការលើទូកនេសាទរយៈពេលវែង (តាមលំដាប់ពីច្រើនមកតិច): ប៉ាក់ណាមនៅខេត្តសាមុតប្រាកាន (២៨នាក់) ផែនៅខេត្តសុងក្លា (១៥នាក់) ផែនៅខេត្តក្លងយ៉ៃ ត្រាត និងប៉ាត់តានី (២នាក់ក្នុងមួយខេត្ត) ខេត្ត សាមុតសាខន និងប្រាជុបគិរីខាន់ (១នាក់ក្នុងមួយខេត្ត) ។

## អាយុជនរងគ្រោះនៅក្នុងពេលជ្រើសរើស

រវាងអាយុ : ១៥-៥៣ ឆ្នាំ)







រូបថត(ខាងស្តាំ) : ជនរងគ្រោះវ័យក្មេងជាងគេចំនួន៣នាក់ដែលបានសង្គ្រោះ ក្នុងចំណោមអ្នកទាំង ៤៩នាក់ ដែលបានសម្ភាសន៍នៅភូមិកំណើតរបស់ខ្លួន។ (ខែ ធ្នូ ឆ្នាំ ២០០៨)

***ចាប់ពីភូមិ ដល់ទូកនេសាទ : បណ្ដាញមេខ្យល់ជាជនជាតិខ្មែរ និងថៃ បានចាត់ចែង ឡើងតាមរូបភាពខុសគ្នាមួយចំនួនដោយបោកប្រាស់ជនរងគ្រោះឱ្យទៅធ្វើការនៅលើទូកនេសាទរយៈពេលពីរឆ្នាំ ឬលើសពីនេះ ក្នុងបំណងកេងប្រវ័ញ្ចកម្លាំងពលកម្ម។***

អ្នករងគ្រោះទាំងអស់ អាចរំឭកឡើងវិញបានយ៉ាងច្បាស់ពីអំពើរំលោភបំពាននានា ដែលពួកគេបានទទួល និងអំពីមេខ្យល់ អ្នកកេងប្រវ័ញ្ច និងទីតាំងដែលពាក់ព័ន្ធនៅក្នុងការរំលោភបំពាន ក៏ដូចជា ទង្វើមិនដូចពាក្យសន្យា។ សេចក្ដីដកស្រង់ដូចខាងក្រោមនេះ បង្ហាញអំពីទិដ្ឋភាពទូទៅមួយអំពីជំពាក់ប្រាក់ខែ (ការមិនព្រមឱ្យប្រាក់កម្រៃឱ្យ ដើម្បីជាលេស ក្នុងការបង្ខំកម្មករមិនឱ្យឈប់ពីការងារដោយស្ម័យប្រាក់ ហើយសង្ឃឹមថា ខ្លួននឹងទទួលបានកម្រៃទាំងអស់ដែលគេនៅជំពាក់) នេះគ្រាន់តែជាការបោកប្រាស់តែប៉ុណ្ណោះ។

*"ខ្ញុំអាចទទួលបាន ៦០០០ បាត ក្នុងមួយខែ ប៉ុន្តែ ខ្ញុំមិនដែលទទួលបានប្រាក់កម្រៃនេះទេ។ ថៅកែខ្ញុំមិនបើកប្រាក់ខែឱ្យខ្ញុំទេ ហើយគាត់ឱ្យខ្ញុំរង់ចាំដល់ខែបន្ទាប់ជារៀងរហូត។ ក្រោយពេលខ្ញុំធ្វើការបាន ១ ឆ្នាំ ខ្ញុំព្យាយាមសុំបើកប្រាក់ខែ។ គាត់ឱ្យខ្ញុំ ២០០០០ បាត សម្រាប់រយៈពេល ១ ឆ្នាំ ដែលខ្ញុំបានធ្វើការឱ្យគាត់។ ខ្ញុំផ្ញើប្រាក់ទាំងអស់មកម្ដាយខ្ញុំនៅកម្ពុជា តាមរយៈ [មេខ្យល់]។ ប៉ុន្តែ[មេខ្យល់] មិនបានបញ្ជូនប្រាក់របស់ខ្ញុំមកឱ្យម្ដាយខ្ញុំឡើយ គាត់យកទុកសម្រាប់ខ្លួនឯង។"* ជនរងគ្រោះម្នាក់អាយុ ២១ ឆ្នាំ មកពីខេត្តព្រៃវែង។

ដូចមានបង្ហាញក្នុងសេចក្ដីដកស្រង់ខាងក្រោមជនរងគ្រោះអាចបញ្ជាក់បានច្បាស់លាស់អំពីសញ្ជាតិរបស់មេខ្យល់ អ្នកដឹកជញ្ជូន និង អ្នកកេងប្រវ័ញ្ចដែលពាក់ព័ន្ធ ពោលគឺ ថាតើពួកគេជាជនជាតិកម្ពុជា ឬ ជនជាតិថៃ។

***សំណួរ : នៅខាងក្នុងប្រទេសថៃ តើមានអ្នកណាម្នាក់ជួយដល់រូបអ្នកដែរឬទេ ... ជួយចាត់ចែងការធ្វើដំណើរ ឬរកការងារធ្វើដែរឬទេ?***

ចម្លើយ : មេខ្យល់ ថៃម្នាក់ បានជួយឱ្យខ្ញុំចូលទៅប្រទេសថៃ និងរកការងារឱ្យខ្ញុំធ្វើ។

***សំណួរ : តើអ្នកបង់ប្រាក់ឱ្យបុគ្គលនោះឬទេ? ប៉ុន្មាន? តើអ្នកដឹងអ្វីខ្លះអំពីបុគ្គលនោះ?***

ចម្លើយ : ខ្ញុំមិនបានបង់ប្រាក់ទៅឱ្យពួកគេទេ។ នៅពេលមេខ្យល់ជាជនជាតិថៃដឹកខ្ញុំទៅកន្លែងការងាររបស់ខ្ញុំ គាត់យក ២.៥០០ បាត ពីថៅកែរបស់ខ្ញុំ ដូច្នេះខ្ញុំត្រូវនៅធ្វើការឱ្យថៅកែ ដើម្បីរកប្រាក់សងគាត់វិញ។ កាលពីមុន ខ្ញុំមិនបានដឹងថាមេខ្យល់ជាជនជាតិខ្មែរ ឬ ថៃឡើយ។ មេខ្យល់ទីមួយជាជនជាតិខ្មែរឈ្មោះ (ឈ្មោះលុបចេញ) គាត់មានអាយុប្រមាណ ២៨-២៩ ឆ្នាំ។ គាត់ជា ជនជាតិខ្មែរ ហើយការងាររបស់គាត់គឺនាំមនុស្សពីកម្ពុជាទៅធ្វើការនៅប្រទេសថៃ។ គាត់ផ្ទេរប្រាក់ពីជនកម្ពុជាដែលកំពុងធ្វើការនៅ ប្រទេសថៃទៅគ្រួសាររបស់ពួកគេនៅកម្ពុជា។ មេខ្យល់ទី២ ជាបុរសជនជាតិខ្មែរដែរនោះ មានអាយុប្រមាណ ២៥ ឆ្នាំ។ ខ្ញុំគិតថាគាត់ អាចជាទាហាន ដោយសារនៅពេលខ្ញុំជួបគាត់ គាត់ស្លៀកពាក់ឯកសណ្ឋានយោធា។ មេខ្យល់ជាជនជាតិថៃមានអាយុប្រមាណ ២៧ ឆ្នាំ គាត់មានឈ្មោះ (ឈ្មោះលុបចោល) ។ ជនរងគ្រោះអាយុ ២៣ ឆ្នាំ មកពីខេត្តព្រៃវែង

ការវិភាគមួយអំពីការជ្រើសរើស/ការជួញដូរជនរងគ្រោះទាំង ៤៩ នាក់ បង្ហាញអំពីទម្រង់ និងទម្លាប់អនុវត្តក្នុងការជួញដូរមនុស្ស។

| ការសន្យាដែលបានធ្វើឡើង និងដែលបានបំពាន<br>សេចក្តីរាយការណ៍អំពីល្បិចកល និងការសន្យារបស់មេខ្យល់ | |
|---|---|
| មេខ្យល់សន្យាចំពោះជនរងគ្រោះអំពីប្រាក់ចំណូលប្រចាំខែនៅក្នុងប្រទេសថៃ | ៣000-៧000 បាត<br>(៨៦-២00 ដុល្លាអាមេរិក) |
| ប្រាក់ចំណូលដែលមេខ្យល់ទទួលបានពីការលក់ជនរងគ្រោះទៅឱ្យម្ចាស់ទូក ឬមេការនៅលើទូកនេសាទ | ១0000-១៥000 បាត<br>(២៨៧-៤៣១ ដុល្លាអាមេរិក) |
| ចំនួនប្រាក់ដែលមេខ្យល់បន្ត និងអ្នកដឹកជញ្ជូនទទួលបាន | ១៥00-២៥00 បាត<br>(៤៣-៧២ ដុល្លាអាមេរិក) |
| ការងារដែលមេខ្យល់សន្យាជាមួយជនរងគ្រោះ | តាមធម្មតាគ្មានការងារជាក់លាក់ទេ ។ ជួនកាល ថាការងារនៅរោងចក្រ ឬការសំណង់ |

---

**ដំណើរឆ្ពោះទៅទាសភាព : បណ្តាញមេខ្យល់/អ្នកជួញដូរមនុស្ស ដែលផ្គត់ផ្គង់កម្មករដល់ទូកនេសាទរយៈពេលវែងដែលប្រកបដោយការកេងប្រវ័ញ្ច**

** ព្រួញក្រហម បង្ហាញពីទំនាក់ទំនងច្បាស់លាស់ជាមួយការកេងប្រវ័ញ្ច ។ ប្រអប់ពណ៌លឿង និងពណ៌លឿងទុំមានតួលេខប្រហែលគ្នានៅក្នុងសំណាកនៃការសិក្សានេះ ។ វិធាន ការឆ្លើយតបនៅក្នុងការអនុវត្តច្បាប់គួរតែផ្តោតលើចំណងទាក់ទងជាមួយការកេងប្រវ័ញ្ច ។*




---

**នៅជីវិតលើទូកដ៏វែងឆ្ងាយ : តាមធម្មតាជនរងគ្រោះរងការកេងប្រវ័ញ្ចធ្ងន់ធ្ងរតាមរូបភាពជាច្រើន នៅលើផ្ទៃសមុទ្រ ដែលរួមទាំង ការវាយក្បាលនិងរូបកាយ បង្អត់អាហារ មិនផ្តល់ប្រាក់កម្រៃ និង ឈឺចាប់ខាងផ្លូវចិត្តដោយឃើញអំពើហឹង្សា និងឃាដកម្ម។**

ជាធម្មតា បុរស និងកុមារទាំងអស់ បានរាយការណ៍ថា ត្រូវទ្រាំទ្រលក្ខខណ្ឌនៃការកេងប្រវ័ញ្ច និងការបង្ខិតបង្ខំដូចតទៅ : ការវាយដំលើរូបរាងកាយ ការគម្រាមដល់អាយុជីវិត បាក់ស្បាតដោយសារឃើញអំពើហឹង្សាចំពោះមុខ ការបាត់បង់ជីវិត និងឃាដកម្ម រយៈពេលធ្វើការជាច្រើន ម៉ោងលើសពីសត្វធាតុ ទៅទៀត (ជួនកាលរហូតដល់បីថ្ងៃបីយប់ជាប់ៗគ្នា) ការឃាត់មិនឱ្យសម្រាក និងបង្អត់របបអាហារ និងលក្ខខណ្ឌ គ្រោះថ្នាក់ធ្ងន់ធ្ងរ ជួនកាលគម្រាមកំហែងដល់ជីវិតក៏មាន។ ទូកនេសាទដែលធ្វើដំណើររយៈឆ្ងាយទាំងអស់អាចចំណាយពេលពីរឆ្នាំ ឬយូរជាងនេះ នៅលើផ្ទៃសាគរ ដែលទទួលការផ្គត់ផ្គង់ពីទូកនានាដែលផ្តល់ភស្តុភា ឥន្ធនៈ អង្ករ និងកម្មករថ្មីៗ (និងប្រមូលយកត្រីទៅវិញ) ក្នុងពេលវិលត្រឡប់មកជិតដល់ប្រទេសថៃ និងតាមធម្មតានាវាត្រូវឈប់សំចតនៅឆ្នេរសារ៉ាវ៉ាក់ នៅពេលស្ថិតក្នុងដែនទឹកប្រទេសម៉ាឡេស៊ី។ យោងតាមសំដីជន រងគ្រោះបុរសត្រូវបានគេលក់ បន្តពីទូកមួយទៅទូកមួយផ្សេងទៀតនៅលើផ្ទៃសមុទ្រ នៅពេលតម្រូវការផ្លាស់ប្តូរកម្លាំង។

*"ជាញឹកញាប់ យើងរងការវាយតប់លើក្បាលផ្នែកខាងក្រោយ និងនៅលើខ្នង ដោយកម្មករជាជនជាតិថៃ។ នាយក្រុមនៅលើទូក មានកាំភ្លើង។ នៅលើឆ្នេរ (សារ៉ាវ៉ាក់) យើងឃើញ មេក្រុមជាជនជាតិថៃ កាត់ក្បាលអ្នកនេសាទម្នាក់ជាជនជាតិវៀតណាម ហើយមេក្រុមជាជនជាតិថៃម្នាក់ទៀត កាត់ក្បាលអ្នកនេសាទម្នាក់ទៀតជាជនជាតិថៃ"។*
ជនរងគ្រោះអាយុ ១៩ ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ

*"ថៅកែរបស់ខ្ញុំប្រើប្រាស់ពាក្យអាក្រក់ៗដាក់ខ្ញុំ វាយខ្ញុំ បង្ខំខ្ញុំឱ្យធ្វើការធ្ងន់ៗ និងគម្រាមថាបើខ្ញុំហ៊ានរត់គេច គាត់នឹងបាញ់ខ្ញុំ ។ នៅសមុទ្រមានរលកធំៗជាច្រើន។ នៅទី នោះ គ្មានសុវត្ថិភាពទេ។ កម្មករម្នាក់ស្លាប់ ដោយសារគាត់ធ្លាក់ទឹក ហើយថៅកែរបស់ ខ្ញុំក៏បានដឹងដែរ ប៉ុន្តែមិនបកទូកទៅជួយ សង្គ្រោះគាត់ ទេ"។*
ជនរងគ្រោះអាយុ ២១ ឆ្នាំ មកពីខេត្តព្រៃវែង

**សមាមាត្រនៃជនរងគ្រោះ ដែលរាយការណ៍ ពីការបានឃើញអំពើឃាដកម្ម**








រូបថត(ខាងលើ) : ឧទាហរណ៏អំពីអួនអូស នៅប៉ាក់ណាម ខេត្តសាមុតប្រាកាន ប្រទេសថៃ (ខែ សីហា ឆ្នាំ ២០០៨)
**Photo credits: UNIAP.**




រូបថត(ខាងលើ) : ទូកអូសអួន នៅខេត្តសុងក្លា ប្រទេសថៃ (ខែ សីហា ឆ្នាំ ២០០៧)

## *បទពិសោធន៍នៅក្រោយការរត់គេចខ្លួនក្នុងប្រទេសថៃ និងម៉ាឡេស៊ី : ការជួញដូរជាថ្មីម្តងទៀត និងការរឹបអូសយកប្រាក់ នៅរង់ចាំជនរងគ្រោះជាច្រើន ដែលបានរត់គេចពីការជួញដូរ*

ក្រោយរត់គេចចេញពីទូក តើមានអ្វីកើតឡើងចំពោះជនរងគ្រោះដែលបានគេចខ្លួនរួចនៅក្នុងប្រទេសម៉ាឡេស៊ី? គំរូនេះបង្ហាញពីការ រើសអើងចំពោះជនរងគ្រោះដែលត្រូវបានគេចាប់ និងធ្វើនិរទេស (ដែលផ្ទុយពីអ្នកដែលត្រូវបានជួញដូរជាថ្មីម្តងទៀតឱ្យទៅធ្វើការនៅក្នុងចំការធំៗនិងដែលគេមិនបានរកឃើញ)។ ទោះជា យ៉ាងណាក៏ដោយ ជាការល្អគឺត្រូវពិនិត្យមើលលទ្ធផលខ្លះៗរបស់ជនរងគ្រោះទាំង ៤៩នាក់នេះ។

គួរកត់សំគាល់ថា គ្មាននរណាម្នាក់ត្រូវបានទទួលការពិនិត្យ ឬ ធ្វើអត្តសញ្ញាណថាជាជនរងគ្រោះ ពីការជួញដូរឡើយ បើផ្អែកតាមច្បាប់ នៃប្រទេសម៉ាឡេស៊ី [៤]។

### ឧទាហរណ៍នានានៃលទ្ធផលក្រោយការគេចខ្លួនរួចនៅក្នុងប្រទេសម៉ាឡេស៊ី

- ត្រូវចាប់ខ្លួន រងការចោទប្រកាន់ពីបទរំលោភលើច្បាប់អន្តោប្រវេសន៍ កាត់ទោស ទទួលទណ្ឌកម្ម (ការផាកពិន័យ និង/ឬ ការវាយ នឹងដំបង) និងធ្វើនិរទេសជាជនចំណាកស្រុកល្មើសច្បាប់ ។
- ដេញចាប់ដោយទីភ្នាក់ងារនៃប្រទេសថៃ ដែលត្រូវគ្នាជាមួយនាយក្រុមនៅលើទូក និងម្ចាស់ទូក (ប៉ុន្តែបានទទួល កិច្ចការពារ ដោយ មន្ត្រីអន្តោប្រវេសន៍នៃប្រទេសម៉ាឡេស៊ី) ។
- លាក់ខ្លួននៅក្នុងព្រៃ លូទឹកស្អុយ ឬទីជនបទ បន្ទាប់មកត្រូវគេរកឃើញ និងលក់ទៅឱ្យធ្វើការនៅចំការ ឬកសិដ្ឋានធំៗ ដោយមេខ្យល់ ជាជនជាតិចិន ម៉ាឡេស៊ី ឬថៃ។
- ឃុំទុកដោយទីភ្នាក់ងារនានា ដែលបន្ទាប់មកបានទាក់ទងជាមួយសមាជិកគ្រួសារជនរងគ្រោះនៅកម្ពុជា និងទារប្រាក់ លោះខ្លួន និង ការអនុញ្ញាតឱ្យជនរងគ្រោះវិលត្រឡប់មកមាតុប្រទេសវិញ។

---

[៤] ច្បាប់នៃប្រទេសម៉ាឡេស៊ី ស្តីពីការប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ ២០០៧)

- ត្រូវបានប្រជាជនម៉ាឡេស៊ីនៅមូលដ្ឋានជួយ ដោយបានផ្តល់ចំណីអាហារ ប្រាក់កាស និងប្រើប្រាស់ទូរស័ព្ទចល័ត ដើម្បី ទាក់ទង មកផ្ទះ និងទាក់ទងនៅនគរបាល។
- ត្រូវបានជនជាតិកម្ពុជាផ្សេងទៀតដែលរស់នៅសារ៉ាវ៉ាក់ និងដែលជាអ្នកបានគេចខ្លួនពីទាសភាពនៅលើផ្ទៃសមុទ្រ កាលពីលើកមុន ជួយ រកការងារធ្វើនៅតាមចំការ "ត្រឹមត្រូវ" ដែលផ្ទុយពីការត្រូវជួញដូរឡើងវិញឱ្យទៅធ្វើការ នៅក្នុងចំការ ដែលរងការ កេងប្រវ័ញ្ច ខ្លាំងជាងមុន។

## *អនុសាសន៍*

អនុសាសន៍ចំនួនបីដែលលើកស្នើខាងក្រោមនេះ គឺបានទទួលពីអ្នកឆ្លើយតបជាច្រើន ទាំងនៅក្នុងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការប្រឆាំងការជួញដូរមនុស្ស និងដែលពាក់ព័ន្ធនៅក្នុងការធ្វើអត្តសញ្ញាណ និងគាំទ្រដល់ជនរងគ្រោះទាំងនេះ។

**អនុសាសន៍ ១: ពង្រឹងការអនុវត្តច្បាប់ និងការសម្របសម្រួល :** ច្បាប់ និងគោលនយោបាយ នៃប្រទេសកម្ពុជា[៥] ថៃ[៦] និងម៉ាឡេស៊ី មាន លក្ខណៈស្របគ្នាយ៉ាងច្រើន ជាមួយស្តង់ដារនិងនិយមន័យអន្តរជាតិ។ ប្រសិនបើយកមកអនុវត្ត គេអាចធ្វើអត្តសញ្ញាណ និងការពារបុរស និង កុមារទាំងនេះ ក្នុងនាមជាជនរងគ្រោះ ពីការជួញដូរមនុស្ស និងដាក់ទណ្ឌកម្មអ្នកដែលឃុំទុកជនទាំងនេះជាទាសករ[៧] ដូចជា :

- ជនរងគ្រោះកាន់តែច្រើនឡើងអាចត្រូវពិនិត្យជាបន្ទាន់ និងធ្វើអត្តសញ្ញាណដោយអាជ្ញាធរនៃប្រទេសម៉ាឡេស៊ី នៅពេលដែលពួកគេ ឡើងគោកក្នុងប្រទេសម៉ាឡេស៊ី បន្ទាន់មកធ្វើមាតុភូមិនិវត្តន៍យ៉ាងឆាប់រហ័ស និងដោយសុវត្ថិភាព តាមរយៈកិច្ចសហប្រតិបត្តិការជា មួយស្ថានទូតកម្ពុជា។ ទាំងប្រទេសកម្ពុជា និងថៃ សុទ្ធតែមានគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់ធ្វើអត្តសញ្ញាណជនរងគ្រោះពី ការជួញដូរ ដែលមានលក្ខណៈស្របគ្នាជាមួយច្បាប់ប្រឆាំងការជួញដូរនៃប្រទេសទាំងនោះ និងបទដ្ឋានអន្តរជាតិ។ វត្តមានគោលការណ៍ណែនាំ និងនីតិវិធីនានាប្រហាក់ប្រហែលគ្នានេះក្នុងប្រទេសម៉ាឡេស៊ី សម្រាប់ការធ្វើអត្តសញ្ញាណជនរងគ្រោះដោយការ ជួញដូរ អាចនឹងពង្រឹងបានយ៉ាងច្រើននូវសមត្ថភាពនៃប្រទេសទាំងបី ក្នុងការបង្ក្រាបទម្រង់បែបនេះ នៃការជួញដូរ មនុស្ស ក៏ដូចជាផ្តល់កិច្ចការពារ ការយកចិត្តទុកដាក់ និងសេវានានា ដល់ជនរងគ្រោះ ដែលជាសិទ្ធិរបស់ពួកគេ ដូចមានចែងនៅក្រោមច្បាប់នៃប្រទេសទាំងបីនេះ។
- គួរមានការចែករំលែកព័ត៌មានសំខាន់ៗរវាងប្រទេសទាំងបី ដើម្បីគាំទ្រដល់ប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ប្រឆាំង អ្នកកេងប្រវ័ញ្ច ធ្ងន់ធ្ងរ ពោលគឺ ម្ចាស់ទូកនិងនាយក្រុមនៅលើទូកនេសាទ ក៏ដូចជា ភ្នាក់ងារដែលមានទំនាក់ទំនងច្បាស់លាស់ជាមួយអ្នកទាំងនេះ ដើម្បី ធ្វើឱ្យឃើញថាមានកំណើនចំនួនអ្នកកេងប្រវ័ញ្ចបែបនេះស្ថិតក្រោមការស៊ើបអង្កេត/ផ្តន្ទាទោស និងចំនួនជនរងគ្រោះកាន់តែច្រើន ត្រូវបានធ្វើអត្តសញ្ញាណ/ទទួលបានការ

---

[៥] ច្បាប់កម្ពុជា ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចខាងផ្លូវភេទ (ឆ្នាំ ២០០៨)

[៦] ច្បាប់ប្រទេសថៃ ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស (B.E. 2551 / 2008).

[៧] ទោះជាយ៉ាងណាក៏ដោយ មកទល់សព្វថ្ងៃនេះ ពុំមានករណីនៃការនាំមកកាត់ទោសនូវអ្នកជួញដូរ ឬ អ្នកកេងប្រវ័ញ្ចណាម្នាក់ក្នុងជំពូកទាំងនេះឡើយ។

ជួយសង្គ្រោះ។ ទាំងប្រទេសកម្ពុជា និងថៃ បានបង្កើតអង្គភាពពិសេសសម្រាប់ពង្រឹងការអនុវត្តច្បាប់ និងការស៊ើបអង្កេតដើម្បីបង្ក្រាបការជួញដូរមនុស្ស[៨]។ ការបង្កើតអង្គភាពប្រហាក់ប្រហែលគ្នានេះនៅក្នុងប្រទេសម៉ាឡេស៊ី ក៏ដូចជា ពង្រីកការសម្របសម្រួលរវាងអង្គភាពទាំងនេះនៅក្នុងប្រទេសទាំងបី និងការកំណត់ជនបង្គោល ច្បាស់-លាស់ សម្រាប់ការប្រាស្រ័យទាក់ទងគ្នា ការចែករំលែកព័តិមាន និងការសម្របសម្រួល អាចពង្រឹងបាន ច្រើនផង ដែរនូវសមត្ថភាពនៃប្រទេសទាំងបី ក្នុងការ បង្ក្រាបទម្រង់នៃការជួញដូរមនុស្សមនុស្សនេះ។

**អនុសាសន៍ ២: ជម្រើសផ្សេងក្នុងរបរចិញ្ចឹមជីវិត :** ក្នុងពេលមានជម្រើសតិចតួចសម្រាប់ការចិញ្ចឹមជីវិត និងការធ្វើសមាហរណកម្មឡើងវិញសម្រាប់បុរស និងកុមារទាំងនេះជាពិសេសនៅក្នុងស្ថានភាពវិបត្តិហិរញ្ញវត្ថុពិភពលោក។ ជម្រើសការងារប្រកបដោយសុវត្ថិភាព និងស្របច្បាប់សម្រាប់បុរសទាំងនេះបើទោះជានៅកម្ពុជា ឬនៅកន្លែងណាផ្សេងក៏ដោយ គួរតែត្រូវបានចាត់ទុកជាអាទិភាពមួយសម្រាប់អ្នកផ្តល់សេវា និង ម្ចាស់ជំនួយ។ យោបល់ពីជនរងគ្រោះបង្ហាញថា ជនរងគ្រោះភាគច្រើនចង់រស់នៅ និងធ្វើការនៅកម្ពុជាជាង ប្រសិនបើពួកគេអាច រកការងារធ្វើ និងប្រាក់ចំណូលប្រកបដោយស្ថិរភាព។

**អនុសាសន៍ ៣: ការទប់ស្កាត់អំពើជួញដូរ :** វិធានការទប់ស្កាត់ជាក់ស្តែង គួរតែត្រូវបានអនុវត្តទាំងនៅប្រភពដើម និងកន្លែងជាទីដៅនានា។ របាយការណ៍នេះផ្តល់នូវព័តិមានយ៉ាងសំខាន់ស្តីពីបណ្តាខេត្តជាប្រភពដើមនៅក្នុងប្រទេសកម្ពុជា ក៏ដូចជា បណ្តាខេត្តជា គោលដៅនៅក្នុងប្រទេសថៃផងដែរ។ ល្បិចកល និងការសន្យាបំភ្លៃដោយអ្នកជ្រើសរើសដែលជនរងគ្រោះទាំង ៤៩ នាក់បានរាយការណ៍ អាចយកទៅ ប្រើប្រាស់ សម្រាប់ជាមូលដ្ឋាន និងសម្រាប់ការធ្វើបច្ចុប្បន្នភាពសារណែនាំសម្រាប់បង្កើនការយល់ដឹងដល់ជនងាយរងគ្រោះដែលជាគោលដៅ។

[៨] នគរបាលកម្ពុជា មានអង្គភាពប្រឆាំងការជួញដូរមនុស្ស។ រាជរដ្ឋាភិបាលថៃ មានអង្គភាពប្រឆាំងការជួញដូរមនុស្ស នៅក្នុងផ្នែកស្ត្រី និងកុមារ នៃក្រសួងនគរបាលថៃ និងនៅក្នុងនាយកដ្ឋានស៊ើបអង្កេតពិសេសនៃក្រសួងយុត្តិធម៌។

# សាយរីន

បណ្ដាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ

**គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិប្រឆាំងនឹងការជួញដូរមនុស្ស (UNIAP): ដំណាក់កាលទី ៣**

---

**ការចេញផ្សាយដោយ សាយរីន** (ខែមិថុនា ឆ្នាំ ២០០៧ - ខែមេសា ឆ្នាំ ២០០៩)

*ដើម្បីទទួលបានអត្ថបទបោះពុម្ព និងជាអេឡិចត្រូនិក ដែលមានជាភាសាអង់គ្លេស ឬ ជាភាសានៅក្នុងតំបន់អាងទន្លេមេគង្គ សូមទាក់ទងមកគម្រោង* ***សាយរីន !***

GMS-01 – ការបង្ហាញអំពីគម្រោង សាយរីន : បណ្ដាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ

GMS-02 – ផ្ដោតលើកត្តាងាយរងគ្រោះចំពោះការជួញដូរមនុស្ស ដោយឡែកពីគ្នានៅក្នុងតំបន់

GMS-03 – វិធីគណនាតាមបែបស្ថិតិ សម្រាប់ប៉ាន់ប្រមាណចំនួនជនរងគ្រោះពីការជួញដូរ

GMS-04 – ស្ថានភាពនៃសកម្មភាពប្រឆាំងការជួញដូរ : ឧបករណ៍មួយសម្រាប់ម្ចាស់ជំនួយនានា

GMS-05 – ហេតុអ្វីជនរងគ្រោះពីការជួញដូរបដិសេធជំនួយ : យោបល់តបពីជនរងគ្រោះនៅក្នុងការជួញដូរនៅអឺរ៉ុប

GMS-06 – ប្រតិបត្តិការឆ្មក់ ការសង្គ្រោះ ដំណោះស្រាយ : រំដោះជនរងគ្រោះពីការកេងប្រវ័ញ្ចខាងផ្លូវភេទ និងពលកម្ម

CB-01 – កម្រងទិន្នន័យនៅក្នុងប្រទេសកម្ពុជា អំពីសកម្មភាពប្រឆាំងការជួញដូរ

CB-02 – ការកេងប្រវ័ញ្ចលើបុរសកម្ពុជានៅលើផ្ទៃសមុទ្រ (ករណីចំនួន ១១ ពីខេត្តកណ្ដាល)

CB-03 –ការជួញដូរបុរសកម្ពុជានៅលើផ្ទៃសមុទ្រ : ព័ត៌មានពិតអំពីការជួញដូរបុរសកម្ពុជាឱ្យទៅធ្វើការលើទូកនេសាទថៃ

TH-01 – ផ្ដើមចេញពីការសម្របសម្រួល ឈានទៅការជួញដូរ : មេខ្យល់ និងភ្នាក់ងារនៅខេត្តសាមុតសាខន ប្រទេសថៃ

TH-02 – តើមេធាវីត្រូវការអ្វីខ្លះ ដើម្បីនាំយកការជួញដូរ និងទាសភាពនៅប្រទេសថៃ មកកាត់ទោស? គោលការណ៍ណែនាំពីមេធាវី សម្រាប់ទីភ្នាក់ងារនៅខ្សែបន្ទាត់ជួរមុខ

UK-01 – ប្រតិបត្តិការបង្ក្រាប ការសង្គ្រោះ ដំណោះស្រាយ : Pentameter 2 : ការវាយប្រហារលើការកេងប្រវ័ញ្ចនៅចក្រភព អង់គ្លេស

**សន្លឹកទិន្នន័យប្រចាំប្រទេស (v. 1.0): កម្ពុជា ចិន ឡាវ ភូមា ថៃ និងវៀតណាម**

ចំពោះព័ត៌មានអំពីគម្រោង **សាយរីន** នៃ UNIAP សូមទាក់ទងមក SIREN@undp.org.

**សាយរីន** គឺជាកិច្ចផ្ដួចផ្ដើមមួយ ដែលគាំទ្រដោយ :


គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិប្រឆាំងនឹងការជួញដូរមនុស្ស

ការិយាល័យគ្រប់គ្រងគម្រោងថ្នាក់តំបន់ (UNIAP/PMO)

United Nations Building
7th Floor, Block B
Rajadamnern Nok Avenue, Bangkok 10200
THAILAND


**www.no-trafficking.org**